## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តតាកែវ**

សំណុំរឿងរដ្ឋប្បវេណីលេខ៖ ១៦៩
ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២២
សាលក្រមលេខ: ០២ "ខ"
ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការខេត្តតាកែវ

បានបើក និងបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ លើសំណុំរឿងរដ្ឋប្បវេណីលេខ ១៦៩ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២២ និងកាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោងប្រាំបួនព្រឹក នៅសាលាដំបូងខេត្តតាកែវ ដោយមានសមាសភាព៖

### ចៅក្រមជំនុំជម្រះ

លោក [redacted] ជាអនុប្រធានសាលាដំបូងខេត្តតាកែវ

### ក្រឡាបញ្ជី

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

**ដើមចោទ៖** ឈ្មោះ [redacted] ស្រីដា ភេទស្រី កើតថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៨៦ ជនជាតិខ្មែរ មុខរបររដ្ឋបាលរោងចក្រ មានទីលំនៅបច្ចុប្បន្ន[redacted] ប្ដីឈ្មោះ [redacted] **សំអឿន** មានកូន ០២នាក់ ។

ដោយមានលោក [redacted] និងលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ។

និង

**ចុងចម្លើយ៖** ឈ្មោះ [redacted] **សំអឿន** ភេទប្រុស កើតថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៨៨ ជនជាតិខ្មែរ មុខរបរលាងឡាន និងម៉ូតូ មានទីកន្លែងកំណើត[redacted] ប្រពន្ធឈ្មោះ [redacted] **ស្រីដា** មានកូន ០២នាក់ ។

ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ ។

### សញ្ញាណរឿងក្ដី

កម្មវត្ថុនៃបណ្ដឹងដើម៖ ដើមចោទសុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោម៖



Scanned with CamScanner

១-សុំឱ្យឈ្មោះ [redacted] ស្រីដា លែងលះពីប្តីឈ្មោះ [redacted] សំអឿន ។

២-សុំសិទ្ធិអំណាចមេបាលើកូនចំនួន ០២នាក់ ដោយកូនទី០១ឈ្មោះ [redacted] ដេវីត ភេទប្រុស កើតថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ និងកូនទី០២ឈ្មោះ [redacted] ធីតា ភេទស្រី កើតថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៤ ។

៣-សុំប្រគល់ទ្រព្យរួមមានដូចជា ឱ្យផ្ទះ ទំហំ៦ម៉ែត្រ X ១២ម៉ែត្រ សាងសង់អំពីថ្ម, ប្រគល់ម៉ូតូហុងដាសេរី០១៨ ចំនួន ០១គ្រឿង, ខ្សែកផ្លាទីន ០១ខ្សែ ទម្ងន់ ៦ជី និងចញ្ចៀនផ្លាទីន ០១វង់ ។

**កម្មវត្ថុនៃបណ្តឹងតបៈ ចុងចម្លើយ (ដើមបណ្តឹងតប) សុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោមៈ**

១-ដីទំហំ២១,៨ម៉ែត្រ X ៥៥ម៉ែត្រ មានទីតាំងស្ថិតនៅផ្លូវ៤១ នៅភូមិត្រាំងបើក ឃុំត្រពាំងបី ស្រុកទឹកឈូក ខេត្តកំពត ។

២-ដីទំហំ១០ម៉ែត្រ X ៤៨ម៉ែត្រ មានទីតាំងស្ថិតនៅភូមិព្រៃស្រឡៅង ឃុំទួលអំពិល ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។

៣-ដីទំហំ៤៥ម៉ែត្រ X ៥៥ម៉ែត្រ, មានទីតាំងស្ថិតនៅភូមិដំណាក់អំពិល ឃុំល្អាង ស្រុកដងទង់ ខេត្តកំពត ។

៤-ដីទំហំ១៩៩៧ម៉ែត្រការ៉េ មានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខៈ ២១០៩១៣១០-០៣៨០ មានទីតាំងនៅភូមិត្រពាំងខ្ទួត ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ។

៥-រថយន្តមួយគ្រឿងម៉ាក់ Lexus LX300 ពណ៌កាំម៉ែ ផលិតឆ្នាំ២០០០ ពាក់ស្លាកលេខភ្នំពេញ 2AN-8523 ជាពីរចំណែកស្មើគ្នា ។

## ក-ពន្យល់ត្រួសៗអំពីរឿងក្តី

នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៩ ដើមចោទឈ្មោះ [redacted] ស្រីដា និងចុងចម្លើយឈ្មោះ [redacted] សំអឿន បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខៈ ០៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ ចេញដោយមេឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ ត្រឹមត្រូវតាមច្បាប់។ នៅអំឡុងពេលរួមរស់ជាមួយគ្នាជាប្តីប្រពន្ធមានកូនចំនួន ០២នាក់គឺ កូនទី០១ឈ្មោះ [redacted] ដវីត ភេទប្រុស កើតថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ និងកូនទី០២ឈ្មោះ [redacted] ធីតា ភេទស្រី កើតថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៤ ដោយកូនទាំង ០២នាក់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ នៅពេលរួមរស់នៅជាមួយគ្នាខ្លួន និងប្តីមានទ្រព្យសម្បត្តិរួមមានដូចខាងក្រោមៈ

-ផ្ទះ ០១កន្លែង ដែលប្តីកំពង់រស់នៅមានទំហំ ៦ម៉ែត្រ X ១២ម៉ែត្រ ជាប្រភេទផ្ទះថ្ម ស្ថិតនៅភូមិទួលត្បែង ឃុំព្រៃវិហារ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។



Scanned with CamScanner

-ផ្ទះ ០១កន្លែងទៀត មានទំហំ ៥ម៉ែត្រ X ៦ម៉ែត្រ ជាប្រភេទផ្ទះឈើ ស្ថិតនៅភូមិជំរះពេន ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ ខ្លួន និងកូនរស់នៅសព្វថ្ងៃ ។

-ម៉ូតូចំនួន ០២គ្រឿង ម៉ូតូម៉ាក់ហុងដាសេ១២៥ ស៊េរីឆ្នាំ២០១៨ ប្តីខ្លួនជាអ្នកប្រើប្រាស់សព្វថ្ងៃ និងម៉ូតូម៉ាក់ហុងដាប៊ិត ស៊េរីឆ្នាំ២០២២ ដែលកូនរបស់ខ្លួនឈ្មោះ [redacted] **ដេវីត** ជិះទៅរៀនរាល់ថ្ងៃ ។

-ខ្លួន និងប្តីមិនមានបំណុលរួមជាមួយគ្នាទេ ។

ដើមចោទឈ្មោះ [redacted] **ស្រីដា** សុំលែងលះពីប្តីឈ្មោះ [redacted] **សំអឿន** ដោយមូលហេតុប្តីខ្លួនលេងល្បែងស៊ីសង បំផ្លាញទ្រព្យសម្បត្តិគ្រួសារ ប្រើប្រាស់ថ្នាំញៀនដើរលេងដាច់យប់ មិនគិតគូរប្រពន្ធកូន និងប្រើអំពើហិង្សាក្នុងគ្រួសារ ដែលជាហេតុធ្វើឱ្យខ្លួនអស់មនោសញ្ចេតនា មិនអាចរួមរស់តទៅអនាគតបានទៀតឡើយ ទើបដើមចោទឈ្មោះ [redacted] **ស្រីដា** បានពាក្យបណ្តឹងសុំលែងលះពីចុងចម្លើយ មកសាលាដំបូងខេត្តតាកែវ នាថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២។ នៅដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២ ចុងចម្លើយឈ្មោះ [redacted] **សំអឿន** ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ បានដាក់ពាក្យបណ្តឹងតបដោយសុំឱ្យតុលាការបែងចែកទ្រព្យសម្បត្តិរួមមានដូចជា:

១-ដីទំហំ២១,៨ម៉ែត្រ X ៥៥ម៉ែត្រ មានទីតាំងស្ថិតនៅផ្លូវ៤១ នៅភូមិត្រាំងបើក ឃុំត្រពាំងបី ស្រុកទឹកឈូក ខេត្តកំពត ។

២-ដីទំហំ១០ម៉ែត្រ X ៤៨ម៉ែត្រ មានទីតាំងស្ថិតនៅភូមិព្រៃស្រឡែង ឃុំទួលអំពិល ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។

៣-ដីទំហំ៤៥ម៉ែត្រ X ៥៥ម៉ែត្រ, មានទីតាំងស្ថិតនៅភូមិដំណាក់អំពិល ឃុំល្អាង ស្រុកដងទង់ ខេត្តកំពត ។

៤-ដីទំហំ១៩៩៧ម៉ែត្រការ៉េ មានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: ២១០៩១៣១០-០៣៨០ មានទីតាំងនៅភូមិត្រពាំងខ្លូត ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ។

៥-រថយន្តមួយគ្រឿងម៉ាក់ Lexus LX300 ពណ៌កាម៉ែ ផលិតឆ្នាំ២០០០ ពាក់ស្លាកលេខភ្នំពេញ 2AN-8523 ជាពីរចំណែកស្មើគ្នា ។

**ខ-ការអះអាងរបស់គាគី៖**

**ខ.១.ការអះអាងរបស់ដើមចោទឈ្មោះ** [redacted] **ស្រីដា** ថា: ខ្លួនបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីជាមួយចុងចម្លើយ នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៩ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១។ ដោយការរួមរស់ជាមួយគ្នាជាប្តីប្រពន្ធបង្កើត



Scanned with CamScanner

បានកូនចំនួន ០២នាក់គឺ កូនទី០១ឈ្មោះ [redacted] **ដេវីត** ភេទប្រុស កើតថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ និងកូនទី០២ឈ្មោះ[redacted]**ធីតា** ភេទស្រី កើតថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៤ ដោយកូនទាំង ០២នាក់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ នៅពេលរួមរស់នៅជាមួយគ្នាមានទ្រព្យសម្បត្តិរួមមានដូចខាងក្រោម:

-ផ្ទះចំនួន ០២កន្លែង (ផ្ទះដែលប្តីកំពុងរស់នៅមានទំហំ ៦ម៉ែត្រ X ១២ម៉ែត្រ ជាប្រភេទផ្ទះថ្ម ស្ថិតនៅភូមិទួលត្បែង ឃុំព្រៃវិហារ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ និងផ្ទះ ០១កន្លែងទៀតមានទំហំ ៥ម៉ែត្រ X ៦ម៉ែត្រ ជាប្រភេទផ្ទះឈើ ស្ថិតនៅភូមិជំរះពេន ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ ខ្លួន និងកូនរស់នៅសព្វថ្ងៃ) ។

-ម៉ូតូចំនួន ០២គ្រឿង (ម៉ូតូម៉ាក់ហុងដាសេ១២៥ ស៊េរីឆ្នាំ២០១៨ ប្តីខ្លួនជាអ្នកប្រើប្រាស់សព្វថ្ងៃ និងម៉ូតូម៉ាក់ហុងដាប៊ិត ស៊េរីឆ្នាំ២០២២ ដែលកូនរបស់ខ្លួនឈ្មោះ [redacted] **ដេវីត** ជិះទៅរៀនរាល់ថ្ងៃ) ។

-ខ្សែករបួទីនទម្ងន់ ០៦វង់ និងជញ្ជៀនប្លាទីន ០១វង់ ។

ចំពោះទ្រព្យសម្បត្តិរួមទាំងនេះ ខ្លួនសុំប្រគល់ឱ្យចុងចម្លើយមាន ផ្ទះទំហំ ៦ម៉ែត្រ X ១២ម៉ែត្រ ជាប្រភេទផ្ទះថ្ម ស្ថិតនៅភូមិទួលត្បែង ឃុំព្រៃវិហារ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ, ម៉ូតូម៉ាក់ហុងដាសេ១២៥ ស៊េរីឆ្នាំ២០១៨ ចំនួន ០១គ្រឿង, ខ្សែករប្លាទីនទម្ងន់ ០៦វង់ និងជញ្ជៀនប្លាទីន ០១វង់។ រីឯទ្រព្យសម្បត្តិរួមមាន ផ្ទះទំហំ ៥ម៉ែត្រ X ៦ម៉ែត្រ ជាប្រភេទផ្ទះឈើ ស្ថិតនៅភូមិជំរះពេន ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ និងម៉ូតូម៉ាក់ហុងដាប៊ិត ស៊េរីឆ្នាំ២០២២ ចំនួន ០១គ្រឿង ខ្លួនសុំសិទ្ធិគ្រប់គ្រង ។

-ខ្លួន និងប្តីមិនមានបំណុលរួមជាមួយគ្នាទេ ។

មូលហេតុដែលខ្លួន សុំអំណាចមេបាលើកូនចំនួន ០២នាក់ ដោយសារចុងចម្លើយធ្លាប់ប្រើប្រាស់គ្រឿងញៀន មិនដែលយកចិត្តទុកដាក់មើលថែរក្សាកូនទាំងពីរទេ ហើយខ្លួនមិនទាមទារអាហារកិច្ចចិញ្ចឹមកូនពីចុងចម្លើយឡើយ។ មូលហេតុ ដែលខ្លួនសុំលែងលះពីប្តីពីព្រោះ ចុងចម្លើយតែងតែមិនគិតគូរប្រពន្ធកូន និងបំផ្លាញទ្រព្យសម្បត្តិនៅផ្ទះមានដូចជា: ដើរលេងដាច់យប់, លេងល្បែងស៊ីសង, យកម៉ូតូទៅបញ្ចាំ, ធ្លាប់បាត់លុយ មាស, អំពើហិង្សាក្នុងគ្រួសារ, គ្រឿងញៀន និងធ្លាប់ធ្វើកិច្ចសន្យាចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨ ទើបខ្លួនអស់មនោសញ្ចេតនា ជាប្តីប្រពន្ធទើបខ្លួនដាក់ពាក្យបណ្តឹងសុំលែងពីប្តី។ ខ្លួននៅតែស្នើសុំលែងលះ និងសុំអំណាចមេបាលើកូន និងសុខចិត្តប្រគល់ផ្ទះឱ្យទៅចុងចម្លើយដូចជា: ផ្ទះទំហំ ៦ម៉ែត្រX ១២ម៉ែត្រ សាងសង់អំពីថ្ម ស្ថិតនៅភូមិទួលត្បែង ឃុំព្រៃវិហារ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ និងម៉ូតូម៉ាក HONDA



Scanned with CamScanner

DREAM ដែលមានផ្លាកលេខ 1Q-6232 ស៊េរី ឆ្នាំ២០១៨ ,ខ្សែករប្លាទីន០១ខ្សែរទម្ងន់ ០៦ជី និងជញ្ចៀនប្លាទីន ០១វង់ ។ ចំពោះទ្រព្យសម្បត្តិដែលចុងចម្លើយបានលើកឡើងនៅក្នុងបណ្តឹងតប ខ្លួនសូមបដិសេធ ទ្រព្យនោះមិនមែនជាទ្រព្យសម្បត្តិរួមនោះទេ។ ខ្លួនមានមូលហេតុថាជាមិនមែនជាទ្រព្យសម្បត្តិរួម ពេលដែលខ្លួនបានរៀបការ នៅឆ្នាំ២០០៩ ដោយឈ្មោះ [redacted] **សំអឿន** គ្មានមុខរបរ (នៅផ្ទះ) នៅឆ្នាំ២០១២ ខ្លួនបានចាក់ដីធ្វើផ្ទះលើដីដែលម្តាយក្មេកចែកឱ្យ ដោយប្រើលុយខ្លួនរកបានសុទ្ធសាធ និងបានខ្ចីលុយបងប្អូនប្រុសខ្លួនខ្លះ ខ្លួនបានកែច្នៃនៅដីម្តាយក្មេកជាបន្តបន្ទាប់ដូចជា ចាក់ដីលុបត្រពាំង ចាក់ដីភូមិបន្ថែម ធ្វើរបងថ្មកម្ពស់ ២ម៉ែត្រកន្លះ ប្រវែង ៧២ ម៉ែត្រជុំវិញដីភូមិ ឥដ្ឋាកមុខផ្ទះ ចាក់សាប ដោយចំណាយលុយសរុបអស់ប្រមាណ USD ៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ដូច្នេះទ្រព្យដែលម្តាយក្មេកចែកឱ្យ ដែលចុងចម្លើយបានលើកឡើង ខ្លួនសូមប្រគល់ឱ្យចុងចម្លើយដូចដែរខ្លួនបានរៀបរាប់នៅក្នុងបណ្តឹងដើម។ ទ្រព្យសម្បត្តិដែលខ្លួនប្រគល់ឱ្យ គឺលើសពីអ្វីដែលម្តាយក្មេកខ្លួនចែកឱ្យទៅទៀត ដោយខ្លួនមិនបានដកចេញការដែលចុងចម្លើយបានបំផ្លាញទ្រព្យសម្បត្តិ និងចំណាយលើការរស់នៅផង។ នៅឆ្នាំ ២០១៤ ទឹកប្រាក់ដែលបានពីការលក់ដីស្រែ ដែលម្តាយក្មេកចែកឱ្យមានចំនួន USD ១២,០០០ (មួយម៉ឺនពីរពាន់) ដុល្លារអាមេរិក ប៉ុន្តែបានដកឱ្យឪពុកក្មេកចំនួន USD ៥,០០ (ប្រាំរយ) ដុល្លារអាមេរិក និងសល់មួយចំនួន ចាយវាយប្រចាំថ្ងៃ និងសងបំណុលដែលខ្វះពេលសាងសង់ផ្ទះ និងចំណាយលើការកែឆ្នៃបន្ថែមនៃផ្ទះ នៅលើដីម្តាយក្មេក ហើយបច្ចុប្បន្នផ្ទះនោះចុងចម្លើយកំពុងរស់នៅ។ ចំពោះការទាមទារត្រង់ចំណុច១.៤ នៃបណ្តឹងតប គឺពុំមែនជាដីរបស់ខ្លួនទេ គឺដីរបស់ប្អូន ហើយការទាមទារទាំង ០៥ចំណុច ដែលចុងចម្លើយថាជាទ្រព្យសម្បត្តិរួម ខ្លួនសូមឱ្យចុងចម្លើយដាក់ភស្តុតាងជូនតុលាការពិនិត្យ ។

**ខ.២.**លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ បានថ្លែងការណ៍ និងធ្វើសេចក្តីសន្និដ្ឋានថា ចំពោះឈ្មោះ [redacted] **សំអឿន** និងឈ្មោះ [redacted] **ស្រីដា** គាត់ទើបតែបានចុះសំបុត្រអាពាហ៍ពិពាហ៍ ជាប្តីប្រពន្ធស្របច្បាប់នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ ពីមុនគឺពួកគាត់រស់នៅបែបអនីតិសង្វាស។ ចំពោះដីដែលចុងចម្លើយទាមទារចំនួន ០៥កន្លែង គឺជាទ្រព្យដោយឡែករបស់កូនក្តីខ្ញុំបាទ ដែលមានឈ្មោះ [redacted] **ស្រីដា** ជាម្ចាស់កម្មសិទ្ធិករតែម្នាក់ឯង ។

**ខ.៣.ការអះអាងរបស់ចុងចម្លើយឈ្មោះ** [redacted] **សំអឿន ថា:** ខ្លួនឯងភាពក្នុងការលែងលះ។ ចំពោះការសុំសិទ្ធិអំណាចមេបាលើកូនចំនួន ០២នាក់ គឺកូនទី០១ឈ្មោះ [redacted] **ដេវីត** ភេទប្រុស កើតថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ និងកូនទី០២ឈ្មោះ [redacted] **ធីតា** ភេទស្រី កើតថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៤ របស់ដើមចោទ ខ្លួនមិនឯកភាពប្រគល់អំណាចមេបាឱ្យទៅប្រពន្ធទេ មូល



Scanned with CamScanner

ហេតុខ្លួនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមកូន ដោយមិនទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនពីដើមចោទទេ។ ចំពោះទ្រព្យសម្បត្តិរួមមាន ផ្ទះទំហំ ៦ម៉ែត្រ X ១២ម៉ែត្រ សាងសង់អំពីថ្មស្ថិតនៅភូមិទួលត្បែង ឃុំព្រៃវិហារ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ និងម៉ូតូម៉ាក HONDA DREAM ដែលមានផ្លាកលេខ 1Q-6232 ស៊េរី ឆ្នាំ២០១៨ ,ខ្សែករប្លាទីន០១ខ្សែរទម្ងន់ ០៦ជី និងជញ្ជៀនប្លាទីន ០១វង់ ខ្លួនឯកភាពទទួលយកពីដើមចោទ។ មេធាវីតំណាងដោយអាណត្តិឯកភាពតាមការលើកឡើងរបស់កូនក្តីខ្លួន ។

ខ.៤.លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានថ្លែងការណ៍ និងធ្វើសេចក្តីសន្និដ្ឋានថា ចុងចម្លើយ(កូនក្តីខ្លួន)បានដាក់ពាក្យបណ្តឹងតប ដើម្បីទាមទារបែងចែកទ្រព្យសម្បត្តិរួម ទី១. ដីទំហំ២១,៨ម៉ែត្រ X ៥៥ម៉ែត្រ មានទីតាំងស្ថិតនៅផ្លូវ៤១ នៅភូមិត្រាំងបើកឃុំត្រពាំងបី ស្រុកទឹកឈូក ខេត្តកំពត។ ទី២. ដីទំហំ១០ម៉ែត្រ X ៤៨ម៉ែត្រ មានទីតាំងស្ថិតនៅភូមិព្រៃស្រឡៃង ឃុំទួលអំពិល ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។ ទី៣. ដីទំហំ៤៥ម៉ែត្រ X ៥៥ម៉ែត្រ, មានទីតាំងស្ថិតនៅភូមិដំណាក់អំពិល ឃុំល្អាង ស្រុកដងទង់ ខេត្តកំពត។ ទី៤. ដីទំហំ១៩៩៧ម៉ែត្រការ៉េ មានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: ២១០៩១៣១០-០៣៨០ មានទីតាំងនៅភូមិត្រពាំងខ្លូត ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។ ទី៥. រថយន្តមួយគ្រឿងម៉ាក Lexus LX300 ពណ៌កាម៉ែ ផលិតឆ្នាំ២០០០ ពាក់ស្លាកលេខភ្នំពេញ 2AN-8523 ជាពីរចំណែកស្មើគ្នា។ ក្រោយរៀបការឆ្នាំ២០០៩ ម្តាយក្មេកបានចែកមេគោមួយក្បាល កូនគោ១ គោឈ្មោល ១ក្បាល ចិញ្ចៀន ០១វង់ លុះដល់ឆ្នាំ២០១៤ ម្តាយរបស់ចុងចម្លើយបានចែកប្រាក់ ឱ្យចំនួន USD ១៥,០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ប្រាក់នេះបានយកទៅទិញដីមួយកន្លែងស្ថិតនៅផ្សារព្រៃល្វា ស្រុកសំរោង ក្នុងតម្លៃ USD ១៨,០០០ (មួយម៉ឺនប្រាំបីពាន់) ដុល្លារអាមេរិក ដោយចូលប្រាក់ខាងប្រពន្ធចំនួន USD ៣,០០០ (បីពាន់) ដុល្លារអាមេរិក។ ក្រោយមកអំឡុងឆ្នាំ២០១៨ បានលក់ដីនោះបានប្រាក់ចំនួន USD ៦០,០០០ (ប្រាំមួយម៉ឺន) ដុល្លារអាមេរិក ហើយបានយកលុយនោះទៅទិញវិញបានជាច្រើនកន្លែង ដោយទិញលក់ៗ និងនៅសល់ចំនួន ០៤កន្លែងដូចបានរៀបរាប់ខាងលើ។ ចំពោះដី និងរថយន្តដែលជាទ្រព្យសម្បត្តិរួមកើតឡើងក្នុងចំណងអាពាហ៍ពិពាហ៍ ដើមចោទពុំបានដាក់ក្នុងបណ្តឹងដើម្បីធ្វើការបែងចែកនោះទេ។ ខ្លួនសូមសំណូមពរឱ្យដើមចោទ ថតចម្លងប្លង់ដីជូនតុលាការពិនិត្យ ។

-ដើមចោទបានអះអាងថា ទ្រព្យសម្បត្តិរួមតាមពាក្យបណ្តឹងតបខ្លួនបដិសេធ មិនមែនទ្រព្យសម្បត្តិរួមដូចចុងចម្លើយលើកឡើងទេ ។

**គ-ចំណុចវិវាទបណ្តឹងដើម៖**



Scanned with CamScanner

គ.១.ចំណុចគ្មានវិវាទ:

-ដើមចោទ និងចុងចម្លើយព្រមព្រៀងលែងលះ ។

-ចុងចម្លើយព្រមទទួលយកនៅទ្រព្យសម្បត្តិដែរដើមចោទប្រគល់ឱ្យ ។

គ.២.ចំណុចវិវាទ:

គ.២.១.ចំណុចវិវាទនៃបណ្តឹងដើម:

-តើចុងចម្លើយព្រមប្រគល់អំណាចមេបាលើកូនទាំង ០២នាក់ គឺកូនទី០១ ឈ្មោះ [redacted] ដេវីត ភេទប្រុស កើតថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ និងកូនទី០២ ឈ្មោះ [redacted] ធីតា ភេទស្រី កើតថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៤ ឱ្យទៅដើមចោទជាអ្នកគ្រប់គ្រងដែរ ឬទេ ?

គ.២.២.ចំណុចវិវាទនៃបណ្តឹងតប:

-តើដីទំហំ២១,៨ម៉ែត្រ X ៥៥ម៉ែត្រ មានទីតាំងស្ថិតនៅផ្លូវ៤១ នៅភូមិត្រាំងបើក ឃុំត្រពាំងបី ស្រុកទឹកឈូក ខេត្តកំពត។ ទី២. ដីទំហំ១០ម៉ែត្រ X ៤៨ម៉ែត្រ មានទីតាំងស្ថិតនៅភូមិព្រៃស្រឡែង ឃុំទួលអំពិល ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។ ទី៣. ដីទំហំ៤៥ម៉ែត្រ X ៥៥ម៉ែត្រ, មានទីតាំងស្ថិតនៅភូមិដំណាក់អំពិល ឃុំល្អាង ស្រុកដងទង់ ខេត្តកំពត។ ទី៤. ដីទំហំ ១៩៩៧ ម៉ែត្រ ការ៉េ មានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: ២១០៩១៣១០-០៣៨០ មានទីតាំងនៅភូមិត្រពាំងខ្ទួត ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។ ទី៥. រថយន្តមួយគ្រឿងម៉ាក់ Lexus LX300 ពណ៌កាម៉ែ ផលិតឆ្នាំ២០០០ ពាក់ស្លាកលេខភ្នំពេញ 2AN-8523 ជាទ្រព្យសម្បត្តិរួមប្តីប្រពន្ធឈ្មោះ [redacted] ស្រីដា និងប្តីឈ្មោះ [redacted] សំអឿន ដែរ ឬទេ ?

ឃ.ការពិនិត្យភស្តុតាង

ឃ.១.ឯកសារជាភស្តុតាងរបស់ដើមចោទ:

-លិខិតបញ្ជាក់ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ ។

-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ ។

-សំបុត្រកំណើត ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ ។

-កិច្ចសន្យា ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨ ។

-លិខិតស្នើសុំចេញ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ ។

-ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍លេខ: ០២១-០៩ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩ ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ [redacted] ស្រីដា ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ [redacted] សំអឿន ។

-សំបុត្របញ្ជាក់កំណើតរបស់ឈ្មោះ [redacted] សំអឿន ។



Scanned with CamScanner

-សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់ឈ្មោះ [redacted] ស្រីដា ។

-សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់ឈ្មោះ [redacted] ដេវីត ។

-សៀវភៅស្នាក់នៅលេខ: ៣៥២៤ ជរព ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤ ។

**ឃ.២.ឯកសារជាភស្តុតាងរបស់ចុងចម្លើយ:**

-ពុំមានអ្វីទេ ។

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលផ្ទាល់មាត់ និងការពិនិត្យភស្តុតាងឃើញថា៖

-ពាក្យបណ្តឹងដើម ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ របស់ដើមចោទធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

-ពាក្យបណ្តឹងតប ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ របស់ចុងចម្លើយធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

-ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៩ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ: ០៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ ចេញដោយមេឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ ត្រឹមត្រូវតាមច្បាប់ ។

-ដើមចោទសុំលែងលះពីចុងចម្លើយមានមូលហេតុថា ចុងចម្លើយលេងល្បែងស៊ីសងបំផ្លាញទ្រព្យសម្បត្តិគ្រួសារ, ប្រើប្រាស់ថ្នាំញៀន, ដើរលេងដាច់យប់ មិនគិតគូរប្រពន្ធកូន និងប្រើអំពើហិង្សាក្នុងគ្រួសារ និងទុកឱកាសឱ្យចុងចម្លើយជាច្រើនលើកច្រើនសារក្នុងការកែប្រែខ្លួន និងមានលិខិតចុះកិច្ចសន្យានៅចំពោះមុខភូមិឃុំ ដឹងលឺផងដែរ ប៉ុន្តែចុងចម្លើយមិនព្រមកែប្រែខ្លួន ដូចក្នុងលិខិតបានសន្យានោះទេ ដែលធ្វើឱ្យដើមចោទអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅអនាគតបានទៀតឡើយ។ ការប្តឹងសុំលែងលះរបស់ដើមចោទមានមូលហេតុច្បាស់លាស់សបត្រមបញ្ញត្តិមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី ។

-ដើមចោទសុំទាមទារមានសិទ្ធិអំណាចមេបាលើកូនចំនួន ០២នាក់ គឺកូនទី០១ ឈ្មោះ [redacted] ដេវីត ភេទប្រុស កើតថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ និងកូនទី០២ ឈ្មោះ [redacted] ធីតា ភេទស្រី កើតថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៤ និងពុំទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនទេ ពីព្រោះដើមចោទមានសមត្ថភាពចំណាយលើកូនរៀនសូត្ររស់នៅប្រចាំថ្ងៃ មើលថែទាំទំនុកបម្រុងគ្រប់បែបយ៉ាងផ្តល់ភាពកក់ក្តៅ និងស្រឡាញ់កូនប្រុសស្រីទាំងពីរនាក់របស់ខ្លួនយ៉ាងខ្លាំង។ ដើមចោទមិនអាចខ្វះកូនទាំងពីរនាក់បានទេ និងរីតតែមិនអាចទ្រាំមើលឃើញកូនជាទីស្រឡាញ់របស់ខ្លួន ដែលទើបមានអាយុ១២ឆ្នាំ និងអាយុ០៨ឆ្នាំ ត្រូវតែបំបែកគ្នាជាបងប្អូនដែលពួកគេ



Scanned with CamScanner

ទាំងពីរនាក់កំពុងរស់នៅជាមួយគ្នា លេងប្រលែងគ្នាយ៉ាងសប្បាយរីករាយជារៀងរាល់ថ្ងៃ។ នេះបញ្ជាក់ឱ្យឃើញថា ការថែទាំកូនទាំងពីរនាក់មានសុវត្ថិភាព និងសុខមាលភាពល្អពេញលេញក្នុងការរស់នៅជាមួយដើមចោទជាម្ដាយ។ កូនប្រុសស្រីទាំងពីរនាក់បានចូលរៀនជាទៀតទាត់ មិនដែលមានការអាក់ខាននោះទេ ដោយមានការថែទាំពីដើមចោទ គប្បីតុលាការសម្រេចឱ្យដើមចោទជាម្ដាយជាអ្នកមានសិទ្ធិអំណាចមេបាលើកូនទាំង ០២នាក់ គឺកូនទី០១ ឈ្មោះ [redacted] ដេវីត ភេទប្រុស កើតថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ និងកូនទី០២ ឈ្មោះ [redacted] ធីតា ភេទស្រី កើតថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៤ ជាអ្នកគ្រប់គ្រងស្របតាមបញ្ញត្តិមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី ។

-ដើមចោទបានអះអាងថា ទ្រព្យសម្បត្តិរួមមាន ផ្ទះចំនួន ០២កន្លែង (ផ្ទះដែលប្ដីកំពុងរស់នៅមានទំហំ ៦ម៉ែត្រ X ១២ម៉ែត្រ ជាប្រភេទផ្ទះថ្ម ស្ថិតនៅភូមិទួលត្បែង ឃុំព្រៃវិហារ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ និងផ្ទះ ០១កន្លែងទៀត មានទំហំ ៥ម៉ែត្រ X ៦ម៉ែត្រ ជាប្រភេទផ្ទះឈើស្ថិតនៅភូមិជំរះពេន ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ ខ្លួន និងកូនរស់នៅសព្វថ្ងៃ), ម៉ូតូចំនួន ០២គ្រឿង (ម៉ូតូម៉ាក់ហុងដាសេ១២៥ ស៊េរីឆ្នាំ២០១៨ ប្ដីខ្លួនជាអ្នកប្រើប្រាស់សព្វថ្ងៃ និងម៉ូតូម៉ាក់ហុងដាប៊ិត ស៊េរីឆ្នាំ២០២២ ដែលកូនរបស់ខ្លួនឈ្មោះ [redacted] ដេវីត ជិះទៅរៀនរាល់ថ្ងៃ), ខ្សែកប្លាទីនចំនួន ០១ខ្សែ ទម្ងន់ ០៦ជី និងជញ្ជៀនប្លាទីន ០១វង់ ។

ចំពោះទ្រព្យសម្បត្តិរួមទាំងនេះ ដើមចោទសុំប្រគល់ឱ្យចុងចម្លើយមាន ផ្ទះទំហំ ៦ម៉ែត្រ X ១២ម៉ែត្រ ជាប្រភេទផ្ទះថ្ម ស្ថិតនៅភូមិទួលត្បែង ឃុំព្រៃវិហារ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ, ម៉ូតូម៉ាក់ហុងដាសេ១២៥ ស៊េរីឆ្នាំ២០១៨ ចំនួន ០១គ្រឿង, ខ្សែកប្លាទីនចំនួន ០១ខ្សែ ទម្ងន់ ០៦ជី និងជញ្ជៀនប្លាទីន ០១វង់។ រីឯទ្រព្យសម្បត្តិរួមមាន ផ្ទះទំហំ ៥ម៉ែត្រ X ៦ម៉ែត្រ ជាប្រភេទផ្ទះឈើ ស្ថិតនៅភូមិជំរះពេន ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ និងម៉ូតូម៉ាក់ហុងដាប៊ិត ស៊េរីឆ្នាំ២០២២ ចំនួន ០១គ្រឿង ដើមចោទសុំសិទ្ធិគ្រប់គ្រង។ គូភាគីបានឯកភាពតាមការព្រមព្រៀង គប្បីតុលាការពិនិត្យ និងសម្រេច ។

-ចុងចម្លើយបានអះអាងថា ទ្រព្យសម្បត្តិរួមតាមពាក្យបណ្ដឹងតបមានៈ ដីទំហំ២១,៨ម៉ែត្រ X ៥៥ម៉ែត្រ មានទីតាំងស្ថិតនៅផ្លូវ៤១ នៅភូមិត្រាំងបើក ឃុំត្រពាំងបី ស្រុកទឹកឈូ ខេត្តកំពត, ដីទំហំ១០ម៉ែត្រ X ៤៨ម៉ែត្រ មានទីតាំងស្ថិតនៅភូមិព្រៃស្រឡៅង ឃុំទួលអំពិល ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ, ដីទំហំ៤៥ម៉ែត្រ X ៥៥ម៉ែត្រ, មានទីតាំងស្ថិតនៅភូមិដំណាក់អំពិល ឃុំល្អាង ស្រុកដងទង់ ខេត្តកំពត, ដីទំហំ១៩៩៧ម៉ែត្រការ៉េ មានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខៈ ២១០៩១៣១០-០៣៨០ មានទីតាំងនៅភូមិត្រពាំងខ្លូត ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ និងរថយន្តមួយគ្រឿងម៉ាក់ Lexus LX300 ពណ៌កាម៉ែ ផលិតឆ្នាំ២០០០ ពាក់ស្លាកលេខ



Scanned with CamScanner

ភ្នំពេញ 2AN-8523 ដែលចុងចម្លើយសុំបែងចែកជាពីរចំណែកស្មើគ្នា តែចុងចម្លើយពុំមានភស្តុតាងអ្វីមកបញ្ជាក់ជូនតុលាការទេ ហើយដើមចោទបដិសេធថា មិនមានទ្រព្យសម្បត្តិរួមដូចចុងចម្លើយលើកឡើងនេះទេ។ ហេតុនេះតុលាការមិនអាចពិចារណា សម្រេចតាមការទាមទាររបស់ចុងចម្លើយឈ្មោះ [redacted] សំអឿន បានទេ។ គប្បីសម្រេចច្រានចោលពាក្យបណ្តឹងតបចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ ជាអសារបង់ ។

-ចុងចម្លើយអះអាងថា ដើមចោទនៅតែសុំលែងលះពីខ្លួន ប៉ុន្តែចុងចម្លើយសុំទាមទារមានអំណាចមេបាលើកូនមួយនាក់ឈ្មោះ [redacted] **ជេវីត** ភេទប្រុស កើតនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ និងមិនទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនទេ។ ការសុំមានអំណាចមេបារបស់ចុងចម្លើយមិនសមហេតុផលទេ ព្រោះថាចុងចម្លើយលេងល្បែងស៊ីសងដើរលេងដាច់យប់ និងប្រើប្រាស់ថ្នាំញៀនដូចមានលិខិតស្នើសុំចេញ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ របស់ប្រធានមណ្ឌល SVDA ខេត្តតាកែវ ជាភស្តុតាងបញ្ជាក់ស្រាប់។ ហេតុនេះតុលាការគប្បីសម្រេចច្រានចោលការទាមទាររបស់ចុងចម្លើយលើបញ្ហានេះ ។

-អ្នកពុំមានអំណាចមេបាលើកូនទាំងពីរនាក់ មានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងកូនបានដោយអនុលោមតាមបញ្ញត្តិមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី ។

-គប្បីរឹបអូសប្រាក់ប្រដាប់ក្តីដែលភាគីដើមចោទបានបង់រួច ស្របតាមបញ្ញត្តិមាត្រា៦៤ ចំណុច២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសម្រេចបញ្ចប់

១-ទទួលស្គាល់ពាក្យបណ្តឹងចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ របស់ដើមចោទឈ្មោះ [redacted] **ស្រីដា** ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ច្រានចោលការទាមទាររបស់ចុងចម្លើយឈ្មោះ [redacted] **សំអឿន** ដូចមាននៅក្នុងពាក្យបណ្តឹងតប ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ ជាអសារបង់ ។

៣-ឱ្យដើមចោទឈ្មោះ [redacted] **ស្រីដា** លែងលះពីចុងចម្លើយឈ្មោះ [redacted] **សំអឿន** ស្របតាមបញ្ញត្តិមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី ។

៤-កំណត់ដើមចោទឈ្មោះ [redacted] **ស្រីដា** ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] **ជេវីត** ភេទប្រុស កើតថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ និងកូនឈ្មោះ [redacted] **ធីតា** ភេទស្រី កើតថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៤ តាមបញ្ញត្តិមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី ។

៤.១-ចុងចម្លើយឈ្មោះ [redacted] **សំអឿន** មានសិទ្ធិចូលជួបប្រាស្រ័យទាក់ទង កូនទាំងពីរនាក់ បានតាមបញ្ញត្តិមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី ។



Scanned with CamScanner

៥-ប្រគល់ទ្រព្យសម្បត្តិរួមឱ្យ៖

ក-ផ្ទះ ទំហំ ៥ម៉ែត្រ x ៦ម៉ែត្រ ជាប្រភេទផ្ទះឈើ មានទីតាំងស្ថិតនៅភូមិជំរះពេន ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ និងម៉ូតូម៉ាក់ហុងដាបិតសេរីឆ្នាំ២០២២ ចំនួន ០១គ្រឿង ឱ្យទៅដើមចោទឈ្មោះ [redacted] **ស្រីដា** ។

ខ-ផ្ទះ ទំហំ ៦ម៉ែត្រ x ១២ម៉ែត្រ ជាប្រភេទផ្ទះថ្ម មានទីតាំងស្ថិតនៅភូមិទួលត្បែង ឃុំព្រៃវិហារ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ, ម៉ូតូម៉ាក់ហុងដាសេ ១២៥ សេរីឆ្នាំ០១៨ ចំនួន ០១គ្រឿង, ខ្សែករផ្លាទីន ០១ខ្សែ ទម្ងន់ ៦ជី និងចញ្ចៀនផ្លាទីន ០១វង់ ឱ្យទៅចុងចម្លើយឈ្មោះ [redacted] **សំអឿន** ។

៦-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទដែលបានបង់រួច ។

**សាលក្រមនេះ** បានប្រកាសនៅសាលាដំបូងខេត្តតាកែវ នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងរយៈពេល ០១ខែ (មួយ)ខែ គិតចាប់ពីថ្ងៃបានទទួលលិខិតសាលក្រមនេះ ។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
តាកែវ, ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣

**ចៅក្រម**

(ហត្ថលេខា និងត្រា) [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ៤រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
តាកែវ, ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**
**ចៅក្រម**

[redacted]



Scanned with CamScanner